## កម្មវិធីអប់រំជនអន្តោប្រវេសន៍រដ្ឋផេនស៊ីលវ៉ានៀ

# កូនសៀវភៅគម្រោងសិក្សាថ្នាក់សញ្ញាបត្រ

---

## មគ្គុទេសក៍ណែនាំសម្រាប់ឪពុកម្តាយរដ្ឋរដ្ឋផេនស៊ីលវ៉ានៀ៖
## វិថីទៅកាន់មហាវិទ្យាល័យនិងអាជីពការងារ

*តុលា 2018 (កែប្រែ)*

**COMMONWEALTH OF PENNSYLVANIA**

**DEPARTMENT OF EDUCATION**

333 Market Street

Harrisburg, PA 17126-0333

www.education.pa.gov

**ខមមិនវែលអូហ្វផេនស៊ីលវ៉ានៀ**

Tom Wolf, អភិបាល

**នាយកដ្ឋានអប់រំ**

Pedro A. Rivera, លេខា

**ការិយាល័យការអប់រំបឋមសិក្សា/មធ្យមសិក្សា**

Matthew Stem, លេខារង

**ការិយាល័យទ្រទ្រង់សាលា**

Sherri Smith, ប្រធាន

**អង្គភាពសេវាសិស្ស**

Carmen Medina, ប្រធាន

នាយកដ្ឋានអប់រំរដ្ឋផេនស៊ីលវ៉ានៀ (PDE) ពុំមានការរើសអើងនៅក្នុងកម្មវិធីអប់រំ សកម្មភាព ឬការអនុវត្តការជ្រើសរើសការងារ ដោយផ្អែកលើមូលដ្ឋានជាតិសាសន៍ ពណ៌សម្បុរ ជាតិកំណើត [ភេទ] យែនឌ័រ ទំនោរផ្លូវភេទ ពិការភាព អាយុ សាសនា ដូនតា សមាជិកភាពក្នុងសហជីព អត្តសញ្ញាណឬការបញ្ជាក់ពីយែនឌ័រ ស្ថានភាពជំងឺអេដស៍ ឬមេរោគអេដស៍ ឬប្រភេទនៃការការពារដោយផ្លូវច្បាស់ផ្សេងទៀត។ ការប្រកាសគោលនយោបាយនេះ គឺត្រូវធ្វើឡើងស្របទៅតាមច្បាប់រដ្ឋ រួមបញ្ចូលទាំងច្បាប់ស្តីពីទំនាក់ទំនងមនុស្សរដ្ឋផេនស៊ីលវ៉ានៀ និងច្បាប់សហព័ន្ធ, រួមទាំងមាត្រា VI  និងមាត្រា VII នៃច្បាប់ស្តីពីសិទ្ធិពលរដ្ឋឆ្នាំ 1964, មាត្រា IX នៃវិសោធនកម្មច្បាប់អប់រំឆ្នាំ 1972, មាត្រា 504 នៃច្បាប់ស្តានីតិសម្បទាឆ្នាំ1973, ច្បាប់ស្តីពីការរើសអើងចំពោះអាយុនៅក្នុងការងារឆ្នាំ1967, និងច្បាប់ស្តីពីពលរដ្ឋអាមេរិកាំងដែលមានពិការភាពឆ្នាំ1990។

បុគ្គលដូចខាងក្រោម ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវលើការសាកសួរពាក់ព័ន្ធនឹងគោលនយោបាយមិនរើសអើងនៃនាយកដ្ឋានអប់រំរដ្ឋផេនស៊ីលវ៉ានៀ។

**សម្រាប់សំណួរពាក់ព័ន្ធនឹងការមិនរើសអើងក្នុងការងារ៖**

Pennsylvania Department of Education

Equal Employment Opportunity Representative

Bureau of Human Resources

ទូរសព្ទជាសំឡេង៖ (717) 783-5446

**សម្រាប់សំណួរពាក់ព័ន្ធនឹងការមិនរើសអើងនៅគ្រប់កម្មវិធីនិងសកម្មភាពទាំងអស់របស់នាយកដ្ឋានអប់រំរដ្ឋផេនស៊ីលវ៉ានៀ៖**

Pennsylvania Department of Education
School Services Unit Director
333 Market Street, 7th Floor, Harrisburg, PA 17126-0333
ទូរសព្ទជាសំឡេង៖ (717) 783-3750, ទូរសារ៖ (717) 783-6802

ប្រសិនបើអ្នកមានសំណួរនានាអំពីការបោះពុម្ពផ្សាយ ឬច្បាប់ថតចម្លងបន្ថែម សូមទំនាក់ទំនង៖

Pennsylvania Department of Education
Bureau of School Support | Division of Student Services
333 Market Street, 3rd Floor, Harrisburg, PA 17126-0333
សំឡេង៖ (717) 783-6466, ទូរសារ៖ (717) 783-6642
www.education.pa.gov

សំណើសុំ/សំណួរផ្នែកសារព័ត៌មានទាំងអស់៖ សូមទំនាក់ទំនងការិយាល័យព័ត៌មាននិងទំនាក់ទំនងតាមរយៈលេខ (717) 783-9802។

# តារាងមាតិកា


អង្គភាពមាតាបិតា – វិថីទៅកាន់មហាវិទ្យាល័យនិងអាជីពការងារ.................................................... 5

ការកំណត់គោលដៅ........................................................................................................ 6

ផែនការមាតាបិតា-សិស្ស ................................................................................................ 8

ការវាយតម្លៃដោយខ្លួនឯងសម្រាប់ឪពុកម្តាយ.........................................................................10

ក្រុមគាំទ្រ ....................................................................................................................12

ឥណទាននៅវិទ្យាល័យ......................................................................................................15

តេស្ត និងយុទ្ធសាស្ត្រក្នុងការធ្វើតេស្ត......................................................................................17

ការធ្វើផែនការសម្រាប់ការអប់រំនៅក្រោយមធ្យមសិក្សា ..................................................................21

កម្មវិធីក្រោយមធ្យមសិក្សា..................................................................................................22

ការបង់ប្រាក់សម្រាប់ការអប់រំក្រោយមធ្យមសិក្សា ........................................................................27

កំណត់ចំណាំ និងធនធានបន្ថែម..........................................................................................31

# អង្គភាពមាតាបិតា – វិថីទៅកាន់មហាវិទ្យាល័យនិងអាជីពការងារ

## បណ្តុំមេរៀន

នេះគឺជាមេរៀនដាច់ដោយឡែកសម្រាប់ឪពុកម្តាយ និងអាណាព្យាបាល។ មេរៀននេះ រួមបញ្ចូលនូវសមាសធាតុពីមេរៀននីមួយៗសម្រាប់សិស្ស។ ទម្រង់ឯកសារមានលក្ខណៈល្អប្រសើរសម្រាប់ឪពុកម្តាយ និងមានចំណុចប្រទាក់ក្រឡាគ្នា។ សម្ភារៈត្រូវអាចប្រើប្រាស់បានដើម្បីគ្របដណ្តប់លើសិក្ខាសាលាចំនួនពីរឬច្រើន។

## ខ្លឹមសារសង្ខេប

- ការកំណត់គោលដៅ និងផែនការឪពុកម្តាយ-សិស្ស
- ក្រុមគាំទ្រ
- ឥណទាននៅវិទ្យាល័យ
- យុទ្ធសាស្ត្រក្នុងការធ្វើតេស្ត
- បញ្ជីត្រួតពិនិត្យការធ្វើផែនការក្រោយមធ្យមសិក្សា

### តើវាមានប្រយោជន៍អ្វីខ្លះចំពោះខ្ញុំ?

គិតត្រឡប់ទៅវិញអំពីចំណុចខ្លាំង ទេពកោសល្យ និងចំណាប់អារម្មណ៍ដែលធ្លាប់បានឃើញនិងកត់សម្គាល់ឃើញនៅពេលកុមារភាព និងស្នើឲ្យគាត់ដាក់បញ្ចូលវាទៅក្នុងឯកសារកសាងអាជីពការងារមួយ។

ធ្វើបញ្ជីមួយដែលមានមិត្តភ័ក្តិ មិត្តរួមការងារ សមាជិកគ្រួសារ ឬសមាជិកសហគមន៍បីឬបួននាក់ ដែលអាចជជែកជាមួយកូនរបស់អ្នកអំពីជម្រើសអាជីពការងារនានាបាន។

សាកសួរកូនរបស់អ្នកអំពីសកម្មភាពសិក្សាពិសេសដែលអាចជួយគាត់ក្នុងការបង្កើតទេពកោសល្យ ជំនាញ ឬចំណាប់អារម្មណ៍។

លើកទឹកចិត្តកូនរបស់អ្នកឲ្យនៅបន្តការសិក្សានៅសាលារៀន។

ស្តាប់ ស្តាប់ ស្តាប់!

ជួយកូនរបស់អ្នកធ្វើការតាមដំណើរការជាជាងជំទាស់នឹងគំនិតនានាដែលពុំយល់ស្របជាមួយ។

អ្នកដឹងច្បាស់ពីអ្វីដែលអាចលើកទឹកចិត្តកូនរបស់អ្នក—ញញឹម និយាយកំប្លែង អោប—ប្រសិនបើកូនអ្នកខកចិត្ត ឬមានអារម្មណ៍តានតឹងខ្លាំង។

អបអរសាទរនៅគ្រប់ដំណាក់កាលទាំងអស់នៅក្នុងទិសដៅត្រឹមត្រូវ—ទោះបីជាចំណុចតូចមួយក៏ដោយ!

# ការកំណត់គោលដៅ

## តើខ្ញុំអាចជួយគាំទ្រដល់ជម្រើសអាជីពការងារកូនរបស់ខ្ញុំបានដោយរបៀបណា?

ក្នុងនាមជាមនុស្សដែលដឹងច្បាស់អំពីកូនជាងគេ ឪពុកម្តាយ និងអាណាព្យាបាល គឺស្ថិតក្នុងតួនាទីពិសេសនិងមានតម្លៃក្នុងការណែនាំកែលម្អនិងផ្តល់ការអប់រំស៊ីជម្រៅ។ ឪពុកម្តាយ និងអាណាព្យាបាលភាគច្រើន មានក្តីបារម្ភអំពីជម្រើសអាជីពការងាររបស់កូនចៅពួកគេ បើទោះបីជាពួកគេមានការសប្បាយចិត្តដែលកូនរបស់ពួកគេរកឃើញនូវអ្វីដែលពួកគេចូលចិត្តធ្វើនៅក្នុងជីវិតរបស់ពួកគេក៏ដោយ។ ក្នុងន័យនេះ អ្នកគប្បីកំណត់គោលដៅសម្រាប់កូនចៅរបស់អ្នក។

### ការកំណត់គោលដៅ

- **ធ្វើការកំណត់គោលដៅដែលមានការពាក់ព័ន្ធតាមដែលអាចធ្វើទៅបាន –** យើងចង់បានអ្វីដែលល្អបំផុតសម្រាប់កូនចៅរបស់យើង។ បង្រៀនកូនរបស់អ្នកឲ្យគិតអំពីការកំណត់និងសម្រេចគោលដៅ។ នេះនឹងជួយឲ្យពួកគេក្លាយជាធនធានដ៏ល្អប្រសើរបំផុតមួយក្នុងការបំពេញការងារ។ នេះនឹងផ្តល់អំណាចដល់ពួកគេដើម្បីគ្រប់គ្រងលទ្ធផលនៅក្នុងជីវិតរបស់ពួកគេ និងផ្តល់ឲ្យពួកគេនូវការទទួលស្គាល់ដែលពួកគេស័ក្តិសមនឹងទទួលបាន។
- **កំណត់គោលដៅរយៈពេលខ្លី និងរយៈពេលវែង –** ការកំណត់គោលដៅប្រៀបដូចកាំបិតមុខពីរដែរ។ គោលដៅរយៈពេលខ្លី និងគោលដៅរយៈពេលវែង ត្រូវមានលក្ខណៈងាយៗ ប្រាកដប្រជា និងអាចសម្រេចបាន។ ធ្វើការជាមួយកូនរបស់អ្នកដើម្បីបែងចែកគោលដៅរយៈពេលវែងទៅជាជំហានខ្លីដែលអាចសម្រេចបាន។ ឧទាហរណ៍៖
    - គោលដៅរយៈពេលវែងនៃការពង្រឹងចំណេះដឹងភាសាអង់គ្លេស នឹងត្រូវមានគោលដៅរយៈពេលខ្លី ដូចជាការរៀនពាក្យថ្មីៗចំនួនបីពាក្យ និងអត្ថន័យនៃពាក្យទាំងនោះក្នុងមួយសប្តាហ៍។ នេះនឹងជួយដល់ការកសាងចំណេះដឹងផ្នែកពាក្យរបស់ពួកគេ។
- **កំណត់ចំណុចខ្លាំង និងចំណុចខ្សោយ –** គំនិតនៃការផ្តល់កាដូដល់កូនរបស់អ្នក ដោយសារការសម្រេចគោលដៅតូចៗដែលមានន័យខ្លឹមសារ នឹងជួយដល់ការរក្សាថាមពលនិងជំនឿជៀជាក់ដោយសារពួកគេនឹងបន្តឆ្ពោះទៅមុខដើម្បីសម្រេចបានសមិទ្ធិផលកាន់តែល្អប្រសើរ។ ជួយដល់ពួកគេក្នុងការសិក្សាអំពីអត្ថប្រយោជន៍នៃការធ្វើឲ្យគោលដៅតូច អាចគ្រប់គ្រងបាន និងមានរយៈពេលខ្លី។
- **កំណត់ពីធនធាននានាដែលមាននៅក្នុងសាលានិងសហគមន៍ប –** គិតអំពីធនធាននានាដែលមាននៅពេលកូនរបស់អ្នកបង្ហាញពីការខកចិត្ត ការអាកអន់ចិត្ត និងភាពតែលតោលគ្មានទីពាំងនៅក្នុងសាលារៀន។

- តើខ្ញុំអាចធ្វើអ្វីបានក្នុងនាមជាឪពុក/ម្តាយដើម្បីជួយដល់កូនរបស់ខ្ញុំឲ្យបញ្ចប់ការសិក្សានៅវិទ្យាល័យ?
- តើអ្នកណាអាចជួយខ្ញុំបាន?
- តើខ្ញុំបានដឹងអំពីលក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សានៅវិទ្យាល័យដែរឬទេ?
- តើអ្វីខ្លះជាបញ្ហាប្រឈមរបស់ខ្ញុំដែលរាំងខ្ញុំមិនឲ្យជួយដល់កូនខ្ញុំបាន?

****សូមស្នើសុំជំនួយពីអ្នកជំនាញខាងជំនួយសិស្សនៅពេលធ្វើផែនការគោលដៅ។

# ផែនការមាតាបិតា-សិស្ស

**តារាងខាងក្រោម បង្ហាញពីគោលដៅសាលារៀន គោលដៅកូនរបស់អ្នក និងគោលដៅរបស់អ្នកក្នុងនាមជាឪពុក**/ម្ដាយ។ បន្ទាប់ពីការធ្វើបញ្ជីគោលដៅ បង្កើតផែនការដើម្បីសម្រេចគោលដៅនេះ បង្ហាញថាតើវាជាគោលដៅរយៈពេលវែង ឬរយៈពេលខ្លី និងដើម្បីកំណត់ពីកាលបរិច្ឆេទគោលដៅ។ នេះគឺជាចំណុចចាប់ផ្ដើម**នៃការសន្ទនាដែលល្អរវាងអ្នកនិងកូនរបស់អ្នក។**

| គោលដៅ | ធ្វើផែនការដើម្បីសម្រេចគោលដៅរបស់ខ្ញុំ (ឧ.ទា. ត្រូវការវគ្គសិក្សា ឬសកម្មភាពនានា) | រយៈពេលវែង ឬ រយៈពេលខ្លី? | កាលបរិច្ឆេទ គោលដៅ |
|---|---|---|---|
| សាលារៀន | | | |
| សិស្ស | | | |
| ឪពុក/ម្ដាយ | | | |

**តើខ្ញុំមានក្ដីបារម្ភអ្វីខ្លះ?**

តើកូនរបស់ខ្ញុំអាចសម្រេចអាជីពការងារនេះដែរឬទេ?

តើកូនរបស់ខ្ញុំមានជំនាញនិងចំណេះដឹងដែលត្រូវការសម្រាប់ការងារប្រភេទនេះដែរឬទេ?

តើកូនរបស់ខ្ញុំធ្វើតាមការសម្រេចចិត្តរបស់ពួកគេដែរឬទេ?

តើកូនរបស់ខ្ញុំអាចជួយខ្លួនឯងក្នុងការបំពេញការងារប្រភេទនេះបានដែរឬទេ?

តើវិធីការងារនេះ តម្រូវឲ្យកូនរបស់ខ្ញុំចាកចេញពីសហគមន៍របស់យើងដើម្បីទៅសិក្សាឬធ្វើការងារដែរឬទេ?

តើអ្វីទៅជាអនាគតរយៈពេលវែងនៃមុខរបរមួយនេះ?

**គន្លឹះសំខាន់សម្រាប់ឪពុកម្តាយ**

ការទំនាក់ទំនងគឺប្រៀបដូច "ផ្លូវទ្វេរទិស" ដែរ។ សិស្សអាចនាំមកនូវព័ត៌មានដែលមានសារៈប្រយោជន៍ពីសាលារៀន និងពីអ្នកគ្រប់គ្រង! ឪពុកម្តាយ រួមទាំងអ្នកដែលមិនបានចូលរៀននៅវិទ្យាល័យ ឬមហាវិទ្យាល័យផង អាចផ្តល់នូវជំបូន្មានល្អបាន!

# ការវាយតម្លៃដោយខ្លួនឯងសម្រាប់ឪពុកម្តាយ

ក្នុងនាមជាឪពុកម្តាយ អ្នកដើរតួនាទីយ៉ាងសំខាន់នៅក្នុង "ក្រុមធ្វើផែនការ" សម្រាប់កូនរបស់អ្នក។ ចាប់ផ្តើមដោយការបង្កើតតួនាទីវិជ្ជមាន និងគាំទ្រដើម្បីធានាថាកូនរបស់អ្នកមានអ្វីគ្រប់យ៉ាងដែលត្រូវការដើម្បីបញ្ចប់ការសិក្សានៅវិទ្យាល័យ។ ធ្វើការជាមួយកូនរបស់អ្នក និងជាមួយសាលារៀនដើម្បីកំណត់ពីជំហាននានាដែលនឹងដឹកនាំទៅរកការងារដែលពេញចិត្ត ឬការអប់រំនៅមហាវិទ្យាល័យក្រោយពីបញ្ចប់ការសិក្សានៅវិទ្យាល័យ។ ប្រើប្រាស់បញ្ជីត្រួតពិនិត្យនេះដើម្បីកំណត់ពីរបៀបដែលអ្នកកំពុងធ្វើផ្នែកទាំងនេះ៖

## ចំណុចខ្លាំង

- ☐ ខ្ញុំជឿជាក់ថាកូនរបស់ខ្ញុំមានសមត្ថភាពក្នុងការបំពេញការងារបានយ៉ាងល្អបំផុតនៅក្នុងវគ្គសិក្សារបស់ពួកគេ។
- ☐ ខ្ញុំធ្វើការក្នុងនាមជាក្រុមមួយជាមួយកូនរបស់ខ្ញុំ ហើយខ្ញុំចូលរួមក្នុងដំណើរការនៃការប្រមូលព័ត៌មានដែលកូនរបស់ខ្ញុំត្រូវការ។
- ☐ ខ្ញុំអាចធ្វើជាគំរូក្នុងការខិតខំប្រែងធ្វើការ ពឹងពាក់លើខ្លួនឯង និងការតស៊ូដើម្បីកូនរបស់ខ្ញុំ។
- ☐ ខ្ញុំជជែកគ្នាជាមួយកូនរបស់ខ្ញុំជាញឹកញាប់អំពីផែនការអនាគតរបស់ពួកគេ ហើយខ្ញុំស្តាប់គំនិតនិងផែនការរបស់ពួកគេ។

## បញ្ហាប្រឈម

- ☐ ខ្ញុំមានការរវល់ក្នុងការងារ និងពុំសូវមានពេលសម្រាប់ជជែកជាមួយកូនរបស់ខ្ញុំនោះទេ។
- ☐ កូនរបស់ខ្ញុំគឺជាមនុស្សដំបូងគេនៅក្នុងក្រុមគ្រួសាររបស់យើងដែលមានគោលដៅទៅសិក្សានៅមហាវិទ្យាល័យ។
- ☐ ពេលខ្លះ ខ្ញុំមានការស្ទាក់ស្ទើរក្នុងចិត្ត ឬមិនដឹងថាត្រូវទៅទីណាដើម្បីទទួលបានជំនួយនោះទេ។
- ☐ ខ្ញុំមិនច្បាស់ថា វគ្គសិក្សាមួយណាដែលកូនរបស់ខ្ញុំត្រូវការនោះទេដើម្បីបញ្ចប់ការសិក្សានៅវិទ្យាល័យ។
- ☐ ខ្ញុំដឹងពីចំណាប់អារម្មណ៍និងចំណង់ចំណូលចិត្តកូនរបស់ខ្ញុំ។
- ☐ ខ្ញុំដឹងអំពីផែនការមហាវិទ្យាល័យ/*អាជីពការងាររបស់កូនខ្ញុំបន្ទាប់ពីបញ្ចប់វិទ្យាល័យ។*

## ការធ្វើផែនការជាមុន

- ☐ ខ្ញុំបានត្រៀមខ្លួនសម្រាប់ធ្វើការលះបង់ផ្នែកហិរញ្ញវត្ថុដើម្បីជួយកូនរបស់ខ្ញុំឲ្យសម្រេចបានជោគជ័យនៅក្នុងសាលា។
- ☐ ខ្ញុំនឹងកំណត់ពីធនធានសម្រាប់ការផ្តល់មូលនិធិសម្រាប់ការអប់រំក្រោយមធ្យមសិក្សា និងមានផែនការសន្សំប្រាក់។
- ☐ ខ្ញុំធ្វើការងារដើម្បីសម្របសម្រួលពេលវេលាក្នុងគ្រួសាររបស់ខ្ញុំ ដើម្បីគាំទ្រដល់ពេលវេលាសិក្សារបស់កូនរបស់ខ្ញុំ។
- ☐ ខ្ញុំអាចជួយណែនាំកូនរបស់ខ្ញុំអំពីការទទួលបានឬការរក្សាការងារឲ្យនៅគង់វង់។
- ☐ ខ្ញុំគាំទ្រចំពោះគោលដៅនិង ចំណាប់អារម្មណ៍ការងារកូនរបស់ខ្ញុំ។
- ☐ ខ្ញុំបានដឹង និងបានត្រៀមខ្លួនដើម្បីគាំទ្រការដឹកជញ្ជូននិងរៀបចំការរស់នៅកូនរបស់ខ្ញុំបន្ទាប់ពីបញ្ចប់ការសិក្សា។



# ក្រុមគាំទ្រ

## សារៈសំខាន់នៃការបង្កើតក្រុមគាំទ្រសម្រាប់ឪពុកម្តាយ

វាពិតជាមានសារៈសំខាន់ណាស់សម្រាប់ឪពុកម្តាយជាជនអន្តោប្រវេសន៍ ដើម្បីយល់ដឹងនិងគាំទ្រដល់អនាគតកូនរបស់ពួកគេដោយធ្វើការផ្សព្វផ្សាយដល់ទីភ្នាក់ងារសហគមន៍ក្នុងមូលដ្ឋាន បណ្ណាល័យ មជ្ឈមណ្ឌលកម្សាន្ត និងអង្គការមូលដ្ឋានជំនឿ ដែលពួកគេកំពុងចូលរួម។ ពួកគេអាចផ្តល់ការគាំទ្រដល់ការសិក្សា និងសកម្មភាពលំហែកម្សាន្ត។ ទាំងអស់នេះ គឺជាគន្លឹះសំខាន់សម្រាប់ជោគជ័យក្នុងការសិក្សា។ ឪពុកម្តាយ និងគ្រូបង្រៀន ឬតួនាទីបុគ្គលគាំទ្រ ពុំអាចជំនួសបានទេ ប៉ុន្តែផ្ទុយទៅវិញត្រូវធ្វើការគាំទ្រ និងពង្រឹងតួនាទីម្នាក់ៗដើម្បីធានានូវជោគជ័យរបស់កូន។ ឪពុកម្តាយ ត្រូវចាត់វិធានការដោយចូលរួម និងគាំទ្រគ្រប់សកម្មភាពទាំងអស់ដែលកូនចៅរបស់ពួកគេចូលរួមដើម្បីជួយកូនចៅពួកគេឲ្យសម្រេចបានគោលដៅរយៈពេលខ្លី និងគោលដៅរយៈពេលវែង។ ឪពុកម្តាយ គ្រូបង្រៀន និងអ្នកគាំទ្រ ត្រូវការកសាងភាពជាដៃគូដើម្បីបង្កើតកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ដើម្បីសម្រេចបានគោលដៅរួមៈ ដើម្បីមើលឃើញពីភាពជោគជ័យរបស់កូនចៅពួកគេ។

# ក្រុមគាំទ្រសម្រាប់ឪពុកម្តាយ

| ភាសា ការគាំទ្រ | សាលារៀន | ទីភ្នាក់ងារសហគមន៍ក្នុងមូលដ្ឋាន | បណ្ណាល័យ | មជ្ឈមណ្ឌលកម្សាន្ត | អង្គការមូលដ្ឋានជំនឿ | សមាជិកគ្រួសារ |
|---|---|---|---|---|---|---|
| សាលារៀនទាំងអស់ ត្រូវមានបណ្តាញជំនួយផ្នែកភាសា។ | ស្គាល់គ្រូបង្រៀន ក្រុមប្រឹក្សា ព្រឹទ្ធបុរស និង បុគ្គលិកជំនួយរបស់កូនអ្នក។ | តើមានការផ្តល់ជូនអ្វីខ្លះនៅក្នុងសហគមន៍នេះ? | តើមានសកម្មភាពអប់រំ និង សិក្ខាសាលាអ្វីខ្លះដែលគេផ្តល់ជូន? | តើមានការគាំទ្រនិងសកម្មភាពកម្សាន្តអ្វីខ្លះដែលគេផ្តល់ជូន? | តើមានប្រភេទសេវាកម្មអ្វីខ្លះដែលពួកគេផ្តល់ជូនដើម្បីជួយដល់កូនចៅរបស់ខ្ញុំ? | ខ្ញុំអាចពឹងពាក់សមាជិកគ្រួសារនេះដើម្បីជួយលើកទឹកចិត្តកូនរបស់ខ្ញុំតាមរយៈដំណាក់កាលនៃការអប់រំរបស់ពួកគេ។ |
| តើអ្នកណាជាមនុស្សដែលល្អបំផុតសម្រាប់ការផ្តល់ជំនួយនេះ? | | | | | | |

# ក្រុមគាំទ្រសម្រាប់ឪពុកម្តាយ

| ជំនួយផ្នែកភាសា | សាលារៀន | សហគមន៍ក្នុងមូលដ្ឋាន<br>ទីភ្នាក់ងារ | បណ្ណាល័យ មជ្ឈមណ្ឌល<br>កម្សាន្ត អង្គការមូលដ្ឋានជំនឿ | ជំនួយគាំទ្រផ្សេងទៀត<br>បណ្តាញសម្រាប់អ្នកណែនាំ |
| --- | --- | --- | --- | --- |
| ទូរសព្ទ________________<br><br>ភាសា________________<br><br>តាមច្បាប់ មណ្ឌលសិក្សាធិការត្រូវផ្តល់ការគាំទ្រដល់អ្នកនិយាយភាសាផ្សេងៗទៀត។ ឪពុកម្តាយ ត្រូវការទទួលបានអ្នកបកប្រែដើម្បីចូលរួមក្នុងកិច្ចប្រជុំឬសកម្មភាពសាលារៀន។ នេះរួមបញ្ចូលទាំងកិច្ចប្រជុំជាមួយគ្រូបង្រៀន អ្នកប្រឹក្សាយោបល់ ព្រឹទ្ធបុរស និងក្រុមគាំទ្រសាលារៀន។ | **គ្រូបង្រៀន**<br>ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែល__________________<br><br>**អ្នកប្រឹក្សាយោបល់**<br>ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែ__________________<br><br>**នាយកសាលា/ព្រឹទ្ធបុរស**<br>ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែល__________________<br><br>**បុគ្គលិកផ្នែកអន្តោប្រវេសន៍**<br><br>ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែល__________________ | **អ្នកសម្របសម្រួល**<br>ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែល__________________<br><br>**បុគ្គលិកករណី**<br>ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែល__________________<br><br>**ប្រធានក្រុម**<br>ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែល__________________ | **បណ្ណារក្ស**<br>ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែល__________________<br><br>**អ្នកដឹកនាំកម្មវិធី**<br>ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែល__________________<br><br>តើកម្មវិធីនេះចាប់ផ្តើមនៅពេលណា?<br>__________________________<br>__________________________<br>__________________________<br>__________________________<br>__________________________<br>__________________________ | ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែល__________________<br><br>ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែល__________________<br><br>ឈ្មោះ__________________<br>ទូរសព្ទ__________________<br>អ៊ីម៉ែល__________________ |

នៅសហរដ្ឋអាមេរិក ឪពុកម្តាយជួបប្រជុំជាមួយគ្រូបង្រៀន អ្នកប្រឹក្សាយោបល់សាលារៀន និងបុគ្គលិកជំនួយផ្សេងទៀត (ដូចជាបុគ្គលិក PA-MEP) ដើម្បីពិភាក្សាអំពីអនាគតកូនរបស់ពួកគេ។

រក្សាឈ្មោះ និងព័ត៌មានទំនាក់ទំនងសម្រាប់អ្នកប្រឹក្សាយោបល់សាលារៀនកូនរបស់អ្នក, គ្រូបង្រៀនដែលគួរទុកចិត្ត, បុគ្គលិក PA-MEP, និងអ្នកណែនាំកូនរបស់អ្នកនៅកន្លែងដែលជិតបំផុត និងទំនាក់ទំនងពួកគេនៅពេលដែលអ្នកត្រូវការដំបូន្មាននិងការគាំទ្រ។

នៅសហរដ្ឋអាមេរិក កុមារអាចមិនឯកភាពគ្នាជាមួយនឹងឪពុកម្តាយរបស់ពួកគេបាន។ ប្រសិនបើអ្នក និងកូនរបស់អ្នកពុំអាចដោះស្រាយបញ្ហាបាន សូមធ្វើការប្រឹក្សាយោបល់ជាមួយអ្នកប្រឹក្សាយោបល់, គ្រូបង្រៀនដែលគួរទុកចិត្ត ឬអ្នកណែនាំកុមារសម្រាប់ធ្វើការដោះស្រាយ។

សូមកុំភ្លេចទំនាក់ទំនង "ក្រុមធ្វើផែនការ" ដើម្បីអបអរចំពោះជោគជ័យផងដែរ!

## ឥណទាននៅវិទ្យាល័យ

សាលារៀននីមួយៗមានលក្ខខណ្ឌនៃការបញ្ចប់ការសិក្សាផ្សេងៗពីគ្នា។ ខាងក្រោមនេះ គឺជាឧទាហរណ៍នៃវិទ្យាល័យក្នុងរដ្ឋផេនស៊ីលវ៉ានៀ។ **បញ្ជីលក្ខខណ្ឌតម្រូវនៃវគ្គសិក្សារបស់កូនអ្នក នឹងមើលទៅស្រដៀងគ្នា ប៉ុន្តែត្រូវប្រាកដថាត្រូវស្វែងយល់ពីលក្ខខណ្ឌតម្រូវជាក់លាក់របស់សាលារៀន ដូចនេះកូនចៅរបស់អ្នកអាចបំពេញតាមលក្ខខណ្ឌតម្រូវទាំងអស់ទាំងស្រុង និងទាន់ពេលវេលា។ ប្រសិនបើអ្នកពុំទទួលបានព័ត៌មានតាមរយៈគេហទំព័រសាលារៀនរបស់អ្នក ត្រូវធ្វើការណាត់ជួបជាមួយនឹងអ្នកប្រឹក្សាយោបល់របស់សាលារៀន។ អ្នកប្រឹក្សាយោបល់ គឺជាមនុស្សល្អបំផុតក្នុងការសាកសួរព័ត៌មាននេះ។**

| វគ្គសិក្សា | ថ្នាក់ទី 9 | ថ្នាក់ទី 10 | ថ្នាក់ទី 11 | ថ្នាក់ទី 12 | ឥណទាន |
|---|---|---|---|---|---|
| ភាសាអង់គ្លេស | 1 | 1 | 1 | 1 | 4 |
| គណិតវិទ្យា | 1 | 1 | 1 | 1 | 4 |
| វិទ្យាសាស្ត្រ | 1 | 1 | 1 | 1 | 4 |
| វិទ្យាសាស្ត្រសង្គម | 1 | 1 | 1 | 1 | 4 |
| ភាសាបរទេស | | | 1 | 1 | 2 |
| មនុស្សសាស្ត្រ | 1 | 1 | | | 2 |
| មុខវិជ្ជាជ្រើសរើសបន្ថែម | | | 1 | 1 | 2 |
| សុខភាព និងអប់រំកាយ | .5 | .5 | .5 | | 1.5 |

| | | | |
|---|---|---|---|
| លក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សាផ្សេងទៀត៖ គម្រោងបញ្ចប់ការសិក្សា ម៉ោងសេវាកម្ម និងការប្រឡងវាយតម្លៃក្រោយបញ្ចប់វគ្គសិក្សា | | សរុប | 23.5 |

សូមបំពេញតារាងខាងក្រោមជាមួយនឹងលក្ខខណ្ឌតម្រូវរបស់មណ្ឌលសិក្សារបស់កូនអ្នក៖

| វគ្គសិក្សា | ថ្នាក់ទី 9 | ថ្នាក់ទី 10 | ថ្នាក់ទី 11 | ថ្នាក់ទី 12 | ឥណទាន |
|---|---|---|---|---|---|
| ភាសាអង់គ្លេស | | | | | |
| គណិតវិទ្យា | | | | | |
| វិទ្យាសាស្ត្រ | | | | | |
| វិទ្យាសាស្ត្រសង្គម | | | | | |
| ភាសាបរទេស | | | | | |
| មនុស្សសាស្ត្រ | | | | | |
| មុខវិជ្ជាជ្រើសរើសបន្ថែម | | | | | |
| សុខភាព និងអប់រំកាយ | | | | | |
| លក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សាផ្សេងទៀត៖ គម្រោងបញ្ចប់ការសិក្សា ម៉ោងសេវាកម្ម និងការប្រឡងវាយតម្លៃក្រោយបញ្ចប់វគ្គសិក្សា | | | | សរុប | |

ប្រសិនបើកូនរបស់អ្នកមានបញ្ហាផ្នែកឥណទាន មានធនធានជាច្រើននៅក្នុងសហគមន៍ សាលារៀន រដ្ឋ និងកម្មវិធីសហព័ន្ធ និងវគ្គសិក្សានៃកម្មវិធីអប់រំជនអន្តោប្រវេសន៍រដ្ឋផេនស៊ីលវ៉ានៀ។ ជជែកគ្នាជាមួយអ្នកជំនាញគាំទ្រសិស្សអំពីទីកន្លែងដើម្បីស្វែងរកធនធានទាំងអស់នេះនៅក្នុងសហគមន៍របស់អ្នក។

**តើអ្នកដឹងទេ?**

នៅក្នុងរដ្ឋផេនស៊ីលវ៉ានៀ កុមារមានសិទ្ធិក្នុងការទទួលបានការអប់រំសាធារណៈ រហូតដល់ពួកគេមានអាយុ 21 ឆ្នាំ - ដោយពុំគិតពីស្ថានភាពអន្តោប្រវេសន៍ សុខភាព ឬសមត្ថភាពពុទ្ធិ ឬសមត្ថភាពរាងកាយនោះទេ។

# តេស្ត និងយុទ្ធសាស្ត្រក្នុងការធ្វើតេស្ត

តារាងនៅទំព័របន្ទាប់ រៀបរាប់ពីតេស្តនានាដែលផ្តល់ជូនសម្រាប់គោលបំណងក្រោយមធ្យមសិក្សា/អាជីពការងារ និងតេស្តសំខាន់របស់រដ្ឋ ដូចជាការប្រឡងក្រោយបញ្ចប់វគ្គសិក្សាជាដើម។

# តេស្តសម្រាប់ជ្រើសរើសចូលរៀនថ្នាក់ទី 11 & 12th ដោយស្ម័គ្រចិត្ត

| តេស្ត | PSAT<br>ដំណាក់កាលដំបូង<br>អាហារូបករណ៍<br>ការវាយតម្លៃ<br>តេស្ត | SAT<br>អាហារូបករណ៍<br>ការវាយតម្លៃ<br>តេស្ត | ច្បាប់<br>អាមេរិក<br>មហាវិទ្យាល័យ<br>តេស្ត | TOFEL<br>តេស្ត<br>ភាសាអង់គ្លេស<br>ជា<br>ភាសា<br>បរទេស | ASVAB<br>សេវាយោធា<br>វិជ្ជាជីវៈ<br>សម្បទា<br>ថ្មពិល |
|---|---|---|---|---|---|
| ថ្នាក់ទី | 11 | 11 និង 12 | 11 និង 12 | 12 | 12 |
| ថ្លៃធ្វើតេស្ត | 16$ | $45 គ្មានតែងសេចក្ដី<br>$60 មានតែងសេចក្ដី | 62$ | 195$ | ពុំគិតថ្លៃ |
| កាលបរិច្ឆេទធ្វើតេស្ត | រដូវរងារ<br>និទាឃរដូវ<br>រដូវក្ដៅ | រដូវស្លឹកឈើជ្រុះ<br>រដូវរងារ<br>និទាឃរដូវ<br>រដូវក្ដៅ | រដូវរងារ<br>និទាឃរដូវ<br>រដូវក្ដៅ | រដូវរងារ<br>និទាឃរដូវ | ត្រូវកំណត់ដោយអ្នកជ្រើសរើសទាហាន |
| ខ្លឹមសារតេស្ត | គណិតវិទ្យា<br>អំណានស៊ីជម្រៅ<br>សំណេរ | អំណាន<br>សំណេរ<br>គណិតវិទ្យា | ភាសាអង់គ្លេស<br>គណិតវិទ្យា<br>អំណាន<br>វិទ្យាសាស្រ្ត | ការនិយាយ<br>សំណេរ<br>អំណាន<br>ការស្ដាប់ | គណិតវិទ្យា<br>វិទ្យាសាស្រ្ត<br>អំណាន<br>អេឡិចត្រូនិក<br>មេកានិក |
| គោលបំណងតេស្ត | ផ្ដល់នូវការត្រៀមរៀបចំសម្រាប់ SAT និងប្រើប្រាស់ដើម្បីឲ្យសិស្សមានសមត្ថភាពក្នុងការប្រគួតប្រជែងអាហារូបករណ៍ថ្នាក់ជាតិ | វាស់វែងការត្រៀមរៀបចំខ្លួនសម្រាប់មហាវិទ្យាល័យ | វាស់វែងការត្រៀមរៀបចំខ្លួនសម្រាប់មហាវិទ្យាល័យ | វាយតម្លៃជំនាញភាសា | កំណត់ពីចំណាត់ថ្នាក់ការងារ/ដាក់បញ្ចូលក្នុងយោធា |

## ការវាយតម្លៃចាំបាច់បំផុតរបស់សាលារៀន

| តេស្ត | PSSAs<br>ស្តង់ដាររដ្ឋ PA<br>ការវាយតម្លៃ | តេស្តវាយតម្លៃក្រោយបញ្ចប់វគ្គសិក្សា | តេស្តសម្រាប់ការទទួលបាន WIDA |
|---|---|---|---|
| ថ្នាក់ទី | 3 - 8 | 11 | K-12 |
| ថ្លៃធ្វើតេស្ត | ពុំគិតថ្លៃ | ពុំគិតថ្លៃ | ពុំគិតថ្លៃ |
| កាលបរិច្ឆេទធ្វើតេស្ត | ខែមេសា | ខែធ្នូ ខែមករា ខែឧសភា | រដូវរងារ |
| ខ្លឹមសារតេស្ត | គណិតវិទ្យា<br>ភាសាអង់គ្លេស- សិល្បៈភាសា<br>វិទ្យាសាស្ត្រ | អក្សរសាស្ត្រ<br>ជីវវិទ្យា<br>ពិជគណិត 1<br>តែងសេចក្តីភាសាអង់គ្លេស | ការស្តាប់<br>ការនិយាយ<br>អំណាន<br>សំណេរ |
| គោលបំណងតេស្ត | វាស់ស្ទង់ភាពជោគជ័យរបស់សិស្សនៅគ្រប់កម្រិតរបស់រដ្ឋ | ការវាយតម្លៃនៅបញ្ចប់វគ្គសិក្សា ដែលរៀបចំដើម្បីដោះស្រាយបញ្ហាសមត្ថភាពចំណេះដឹង | ដើម្បីកំណត់ពីការប្រឡងជ្រើសរើស ESL |

បន្ទាប់មកទៀត គឺគំរូប្រតិទិនដែលអ្នកអាចប្រើប្រាស់ដើម្បីកត់ត្រាពីថ្ងៃធ្វើតេស្តកូនរបស់អ្នក។

| SUNDAY | MONDAY | TUESDAY | WEDNESDAY | THURSDAY | FRIDAY | SATURDAY |
| --- | --- | --- | --- | --- | --- | --- |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

សរសេរអ្វីដែលអ្នកនឹងធ្វើជាមួយកូនរបស់អ្នកដើម្បីប្រាកដថាពួកគេជោគជ័យនៅក្នុងការធ្វើតេស្តរបស់ពួកគេ។

| នៅមុនពេលធ្វើតេស្តៈ |
| --- |
| ក្រោយពីការធ្វើតេស្តៈ |

## ការធ្វើផែនការសម្រាប់ការអប់រំនៅក្រោយមធ្យមសិក្សា

ផ្នែកនេះបញ្ជាក់សំខាន់អំពីជំហាននានាដែលឪពុកម្តាយអាចអនុវត្តបានដើម្បីរៀបចំការអប់រំនៅក្រោយមធ្យមសិក្សា។ ការពិភាក្សាទាំងនេះ និងការរៀបចំ ត្រូវចាប់ផ្តើមឲ្យបានឆាប់រហ័ស និងពាក់ព័ន្ធនឹងអ្នកអប់រំជំនួយ អ្នកណែនាំ សមាជិកគ្រួសារ និងមិត្តភ័ក្រ តាមដែលអាចធ្វើទៅបាន។

### តើប្រភេទនៃសាលារៀន/កម្មវិធីក្រោយមធ្យមសិក្សា ស៊ីគ្នាជាមួយនឹងទេពកោសល្យនិងចំណាប់អារម្មណ៍របស់កូនខ្ញុំដែរឬទេ?

- ឪពុកម្តាយ ត្រូវចាប់ផ្តើមការសន្ទនាជាមួយកូនចៅរបស់ពួកគេអំពីជម្រើសក្រោយមធ្យមសិក្សាឲ្យបានឆាប់បំផុតតាំងពីថ្នាក់ទី 8 ឬថ្នាក់ទី ៩។
- មហាវិទ្យាល័យនីមួយៗ សាលាពាណិជ្ជសាស្ត្រ និងសាកលវិទ្យាល័យនៅសហរដ្ឋអាមេរិក មានលក្ខខណ្ឌតម្រូវផ្ទាល់ខ្លួនសម្រាប់ការអនុញ្ញាតឲ្យចូលរៀន។ ឪពុកម្តាយ អាចស្វែងរកព័ត៌មានទាំងអស់នេះបានតាមប្រព័ន្ធអនឡាញ ឬតាមរយៈអ្នកប្រឹក្សាយោបល់សាលារៀន ឬបុគ្គលិកជំនួយដល់ជនអន្តោប្រវេសន៍។
- ឪពុកម្តាយ គប្បីគាំទ្រដល់កូនចៅរបស់ពួកគេក្នុងការចូលរួមជាមួយកម្មវិធីត្រៀមខ្លួនសម្រាប់មហាវិទ្យាល័យ ដែលមាននៅតាមមជ្ឈមណ្ឌលសិក្សាធិការនីមួយៗ។

# កម្មវិធីក្រោយមធ្យមសិក្សា

| ប្រភេទមហាវិទ្យាល័យ | អ្វីដែលអ្នកអាចទទួលបាន | ឧទាហរណ៍ការងារ | លក្ខណៈពិសេស |
|---|---|---|---|
| ការបណ្តុះបណ្តាលការងារដំបូង/ការបណ្តុះបណ្តាលនៅក្នុងការងារ | ☐ លិខិតតែងតាំងដែលទទួលស្គាល់ដោយជាតិពីក្រសួងការងារសហរដ្ឋអាមេរិក<br>☐ ការងារទទួលបានប្រាក់បៀវត្សរ៍<br>☐ ឥណទានមហាវិទ្យាល័យដែលគ្មានបំណុល<br>☐ ចំណេះដឹងនិងជំនាញពាក់ព័ន្ធនឹងកន្លែងការងារ | ☐ អ្នកបង្កើតសុហ្វវែរ<br>☐ គ្រូពេទ្យឯកទេសឱសថស្ថាន<br>☐ មេកានិកវិទ្យា<br>☐ ជំនួយគិលានុប្បដ្ឋាកដែលមានការបញ្ជាក់ត្រឹមត្រូវ<br>☐ កម្មករសំណង់ជំនាញ<br>☐ ជាងអគ្គិសនី<br>☐ ជាងផ្សារដែក | ☐ ការចាប់ផ្តើមការងារពីថ្ងៃទីមួយ<br>☐ ការដំឡើងប្រាក់ឈ្នួល<br>☐ ប្រាក់ឈ្នួលប្រកួតប្រជែងពេញមួយជីវិត |
| ពាណិជ្ជសាស្ត្រ/បច្ចេកទេសសាលារៀន | ☐ វិញ្ញាបនបត្រ<br>☐ សញ្ញាបត្រ<br>☐ បរិញ្ញាបត្ររង | ☐ អ្នកសរសេរកម្មវិធីកុំព្យូទ័រ<br>☐ ជាងសម្អាង<br>☐ ជំនួយការទន្តពេទ្យ<br>☐ ជាងមេកានិក<br>☐ ជំនួយវេជ្ជសាស្ត្រ<br>☐ អ្នកបួមល្ង | ☐ ចំនួនសិស្សតិច<br>☐ ផ្តល់ជូនថ្នាក់រៀនពេលល្ងាចនិងចុងសប្តាហ៍<br>☐ ផ្តោតជាសំខាន់លើជំនាញចាំបាច់សម្រាប់អាជីពការងារជាក់លាក់ |
| សហគមន៍មហាវិទ្យាល័យ | ☐ វិញ្ញាបនបត្រ<br>☐ សញ្ញាបត្រ<br>☐ បរិញ្ញាបត្ររង<br>☐ សមត្ថភាពក្នុងការផ្ទេរទៅសិក្សារយៈពេល 4 ឆ្នាំនៅមហាវិទ្យាល័យ ឬសាកលវិទ្យាល័យ | ☐ គណនេយ្យករ<br>☐ ជាងមេកានិកយន្តហោះ<br>☐ ជំនួយផ្នែកច្បាប់<br>☐ អមវេជ្ជសាស្ត្រ<br>☐ អ្នកធ្វើអនាម័យធ្មេញ<br>☐ ប្រធានគ្រប់គ្រងភោជនីយដ្ឋាន | ☐ ចំនួនសិស្សតិច<br>☐ ផ្តល់ជូនថ្នាក់រៀនពេលល្ងាចនិងចុងសប្តាហ៍<br>☐ ជាទូទៅអាចផ្ទេរទៅសិក្សារយៈពេល 4 ឆ្នាំនៅមហាវិទ្យាល័យ ឬសាកលវិទ្យាល័យ<br>☐ ជាទូទៅមានសាលាតូចៗនៅក្នុងសហគមន៍ |
| ការសិក្សារយៈពេល 4 ឆ្នាំនៅមហាវិទ្យាល័យ ឬសាកលវិទ្យាល័យ | ☐ សញ្ញាបត្របរិញ្ញាបត្រ<br>☐ សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់<br>☐ សញ្ញាបត្របណ្ឌិត<br>☐ សញ្ញាបត្រជំនាញវិជ្ជាជីវៈ | ☐ វិស្វករ<br>☐ អ្នករចនាក្រាហ្វិក<br>☐ ឱសថការី<br>☐ អាកាសយានិក<br>☐ បុគ្គលិកសង្គមកិច្ច<br>☐ គ្រូបង្រៀន | ☐ មនុស្សភាគច្រើនចូលរៀនវគ្គសិក្សាពេញម៉ោង<br>☐ អាចចូលរៀនក្នុងថ្នាក់រៀនខុសគ្នាជាច្រើនបាន<br>☐ ជាទូទៅមានអន្តេវាសិកដ្ឋាននៅក្នុងទីតាំងសាលា |

## ពាក្យគន្លឹះ

**សញ្ញាបត្របរិញ្ញាបត្ររង៖** គឺជាប្រភេទសញ្ញាបត្រមួយដែលប្រគល់ជូនទៅសិស្សនៅមហាវិទ្យាល័យសហគមន៍សហរដ្ឋអាមេរិក ជាទូទៅក្រោយបញ្ចប់ការសិក្សារយៈពេលពីរឆ្នាំ ។

**សញ្ញាបត្របរិញ្ញាបត្រ៖** គឺជាសញ្ញាបត្រប្រគល់ជូនដល់និស្សិតដែលបានបញ្ចប់ការសិក្សារយៈពេលបួនឆ្នាំនៅមហាវិទ្យាល័យ។

**អាជីពការងារ៖** ការងារដែលអ្នកឬកូនរបស់អ្នកទទួលបានការបណ្តុះបណ្តាល។

**មហាវិទ្យាល័យ៖** ការអប់រំណាមួយបន្ទាប់ពីថ្នាក់វិទ្យាល័យដែលផ្តល់សញ្ញាបត្រមួយដល់កូនរបស់អ្នក។

**មហាវិទ្យាល័យសហគមន៍៖** គឺមហាវិទ្យាល័យនានាដែលផ្តល់ជូននូវការអប់រំរយៈពេលពីរឆ្នាំដំបូងនៃការសិក្សារយៈពេលបួនឆ្នាំនៅមហាវិទ្យាល័យ ឬត្រៀមរៀបចំសិស្សសម្រាប់ការងារជាក់លាក់មួយចំនួន។

**សញ្ញាបត្រ៖** ជាអ្វីដែលកូនរបស់អ្នកទទួលបាននៅពេលគាត់បញ្ចប់ការសិក្សាពីមហាវិទ្យាល័យដូចជាសញ្ញាបត្របរិញ្ញាបត្ររង ឬញ្ញាបត្របរិញ្ញាបត្រជាដើម។

**មហាវិទ្យាល័យបច្ចេកទេស៖** គឺមហាវិទ្យាល័យនានាដែលផ្តល់ជូនវគ្គសិក្សា និងកម្មវិធីការងារជាច្រើន ដែលបង្រៀនអំពីចំណេះនិងជំនាញជាក់លាក់ដែលនាំទៅរកការងារណាមួយ។

**សាកលវិទ្យាល័យ៖** ជាប្រភេទនៃសាលារៀនដែលផ្តល់ជូននូវសញ្ញាបត្រ និងមុខវិជ្ជាសិក្សាជាច្រើន។ ការលើកលែងចំពោះថ្លៃសេវាពាក្យស្នើសុំ គឺអាចស្វែងរកបានសម្រាប់អ្នកដែលមានតម្រូវការតាមរយៈអ្នកប្រឹក្សាយោបល់សាលារៀន។

## សមាសធាតុស្នូលទាំងប្រាំសម្រាប់សំណេរកថាខណ្ឌល្អដែលឪពុកម្តាយត្រូវការយល់ដឹង

1. ការចូលរួមជាមួយសហគមន៍ និងសកម្មភាពសាលារៀន នឹងផ្តល់នូវបទពិសោធន៍ដែលនឹងជួយសម្របសម្រួលដល់ដំណើរការនៃសំណេរកថាខណ្ឌ។
2. ការដែលមិនមានសំណេរកថាខណ្ឌអាចនាំឲ្យមានការពន្យារពេលដំណើរការពាក្យស្នើសុំ។
3. ឲ្យគ្រូបង្រៀនម្នាក់ជួយពិនិត្យសំណេរកថាខណ្ឌកូនរបស់អ្នកនៅមុនពេលប្រគល់ពាក្យស្នើសុំ។
4. គាំទ្រកូនរបស់អ្នកនៅក្នុងដំណើរការសំណេរកថាខណ្ឌ និងត្រូវមានមជ្ឈដ្ឋានដែលមានស្ថានភាពល្អប្រសើរ។
5. តាមដានវឌ្ឍនភាពកូនរបស់អ្នក និងសាកសួរពួកគេអំពីវិធីផ្សេងទៀតដែលអ្នកអាចជួយកូនរបស់អ្នកបាន។

## ការត្រៀមរៀបចំសម្រាប់ការអប់រំនៅក្រោយថ្នាក់មធ្យមសិក្សា

## បញ្ជីត្រួតពិនិត្យសម្រាប់ឪពុកម្ដាយ

**ថ្នាក់ទី 9**

☐ កំណត់ពេលវេលាប្រជុំជាមួយអ្នកប្រឹក្សាយោបល់សាលារៀនកូនរបស់អ្នកដើម្បីប្រាកដថាកូនរបស់អ្នកមិនកំពុងស្ថិតក្នុងការតាមដាន និងប្រាកដថាបានចុះឈ្មោះចូលរៀនក្នុងថ្នាក់សិក្សាដែលបំពេញបានតាមលក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សា ហើយនឹងត្រៀមរៀបចំកូនរបស់អ្នកសម្រាប់ការអប់រំនៅក្រោយថ្នាក់មធ្យមសិក្សា សេវាយោធា ឬការងារណាមួយ។

☐ សាកសួរអ្នកអ្នកប្រឹក្សាយោបល់កូនរបស់អ្នក ថាតើវិទ្យាល័យនោះមានផ្ដល់ជូននូវជម្រើសអប់រំវិជ្ជាជីវៈសម្រាប់ថ្នាក់ទី 10 ដែរឬទេ ប្រសិនបើអ្នកចាប់អារម្មណ៍។

☐ ពិភាក្សាជាមួយកូនរបស់អ្នកអំពីផែនការដែលអាចធ្វើបានដើម្បីសន្សំប្រាក់សម្រាប់មហាវិទ្យាល័យ ប្រសិនបើអ្នកពុំទាន់បានធ្វើវានៅឡើយ។

☐ ជជែកគ្នាជាមួយកូនរបស់អ្នកអំពីចំណាប់អារម្មណ៍ការងារ (Onet.org/miproximopaso.org) – pacareers.org

☐ សិក្សាស្វែងយល់អំពីថ្លៃចំណាយ ប្រាក់សន្សំ និងជំនួយហិរញ្ញវត្ថុ។

☐ លើកទឹកចិត្តកូនរបស់អ្នកដើម្បីឲ្យចូលរួមក្នុងសកម្មភាពកម្មវិធីសិក្សាបន្ថែម និងកសាងបំណិនជីវិតដូចជា ភាពជាអ្នកដឹកនាំ ការពឹងពាក់លើខ្លួនឯង ការច្នៃប្រឌិត ការងារក្រុម ការធ្វើសេចក្ដីសម្រេចចិត្ត និងចំណេះដឹងហិរញ្ញវត្ថុ។

**ថ្នាក់ទី 10**

☐ ជួបជាមួយអ្នកប្រឹក្សាយោបល់សាលារៀនកូនរបស់អ្នកដើម្បីប្រាកដថាពួកគេកំពុងស្ថិតក្នុងដំណើរឆ្ពោះទៅរកការបញ្ចប់ការសិក្សា។

☐ ធ្វើការស្រាវជ្រាវតាមអ៊ីនធឺណិត ឬបណ្ណាល័យសាធារណៈដើម្បីស្វែងរកព័ត៌មានអំពីមហាវិទ្យាល័យ/កម្មវិធីសាលារៀនបច្ចេកទេស ថ្លៃសាលា និងថ្លៃចំណាយផ្សេងៗ និងអាហារូបករណ៍។

☐ រំឭកកូនរបស់អ្នកឲ្យបន្តការសិក្សានៅក្នុងថ្នាក់ដែលបំពេញតាមលក្ខខណ្ឌបញ្ចប់ការសិក្សា និងបង្កើតជំនាញ។

☐ បន្តលើកទឹកចិត្តកូនរបស់អ្នកឲ្យចូលរួមក្នុងសកម្មភាពកម្មវិធីសិក្សាបន្ថែម ឬសកម្មភាពស្ម័គ្រចិត្ត។

☐ លើកទឹកចិត្តកូនរបស់អ្នកឲ្យធ្វើទស្សនកិច្ចមហាវិទ្យាល័យ/សាលាបច្ចេកទេស និងចូលរួមក្នុងកម្មវិធីត្រៀមខ្លួនសម្រាប់មហាវិទ្យាល័យក្នុងរដូវក្ដៅ ប្រសិនបើមាន។

**ថ្នាក់ទី 11**

☐ សាកសួរអ្នកប្រឹក្សាយោបល់សាលារៀនកូនរបស់អ្នកដើម្បីប្រាកដថាកូនរបស់អ្នកកំពុងស្ថិតក្នុងដំណើរឆ្ពោះទៅរកការបញ្ចប់ការសិក្សា។

☐ រំឭកកូនរបស់អ្នកដើម្បីចុះឈ្មោះចូលរៀននៅក្នុងវគ្គសិក្សាចាំបាច់សម្រាប់ការបញ្ចប់ការសិក្សា និង/ឬការងារដែលចាប់អារម្មណ៍។

☐ រំឭកកូនរបស់អ្នកឲ្យចុះឈ្មោះប្រឡង PSAT នៅក្នុងរដូវស្លឹកឈើជ្រុះ ប្រសិនបើចាំបាច់ (ប្រសិនបើមិនច្បាស់ សូមជជែកជាមួយអ្នកប្រឹក្សាយោបល់។)

☐ ធ្វើបញ្ជីមហាវិទ្យាល័យ/សាលាបច្ចេកទេស និងកម្មវិធីនានាដែលកូនរបស់អ្នកចាប់អារម្មណ៍។

☐ ស្រាវជ្រាវនិងបង្រួមចំនួនមហាវិទ្យាល័យ/សាលាបច្ចេកទេស និងមុខមុខវិជ្ជាសិក្សា និងការងារឲ្យបានតិចតាមដែល

អាចធ្វើទៅបានជាមួយកូនរបស់អ្នក។

- ☐ រំឭកកូនរបស់អ្នកឲ្យចុះឈ្មោះនៅក្នុង SAT និង/ឬ ACT នារដូវផ្ការីក។
- ☐ រំឭកកូនរបស់អ្នកឲ្យត្រៀមខ្លួនសម្រាប់ SAT ឬ ACT។ និយាយអំពីសារៈសំខាន់នៃកម្មវិធីនេះ (តើលទ្ធផលនេះអាចជះឥទ្ធិពលដល់ពួកគេក្នុងការចូលរួមក្នុងមហាវិទ្យាល័យ និងអាហារូបករណ៍យ៉ាងដូចម្ដេច)។
- ☐ លើកទឹកចិត្តកូនរបស់អ្នកឲ្យបន្តស្វែងយល់បន្ថែម និងធ្វើការសម្រេចចិត្តអំពីមុខវិជ្ជាសិក្សា និងអាជីពការងារ។
- ☐ បន្តលើកទឹកចិត្តកូនរបស់អ្នកឲ្យទៅមើលមហាវិទ្យាល័យ/សាលាបច្ចេកទេសនៅក្នុងឆ្នាំនោះ។ ត្រូវមានការយល់ដឹងអំពីដំណើរកម្សាន្តរបស់មហាវិទ្យាល័យដែលសាលារៀនកូនរបស់អ្នកផ្ដល់ជូន។
- ☐ ធ្វើបញ្ជីមហាវិទ្យាល័យ/សាលាបច្ចេកទេសយ៉ាងតិចចំនួនប្រាំដែលផ្ដល់នូវវគ្គសិក្សាដែលកូនរបស់អ្នកមានចំណាប់អារម្មណ៍។
- ☐ រំឭកកូនរបស់អ្នកឲ្យត្រៀមខ្លួនសម្រាប់ SAT ប្រសិនបើពួកគេកំពុងគិតអំពីកម្មវិធីនេះនៅឆ្នាំបញ្ចប់ ប្រសិនបើចាំបាច់។
- ☐ បន្តប្រាប់ខ្លួនឯងអំពីជំនួយហិរញ្ញវត្ថុ និងជជែកជាមួយអ្នកប្រឹក្សាយោបល់ណែនាំកូនរបស់អ្នក។ ជួយកូនរបស់អ្នកស្រាវជ្រាវរកអាហារូបករណ៍ ដែលស៊ីគ្នាជាមួយនឹងតម្រូវការហិរញ្ញវត្ថុរបស់អ្នក។
- ☐ លើកទឹកចិត្តកូនរបស់អ្នកឲ្យធ្វើផែនការសកម្មភាពនារដូវក្ដៅ៖ ការងារស្ម័គ្រចិត្ត ចូលរួមក្នុងកម្មវិធីរដូវក្ដៅ ឬស្វែងរកការងារ ឬការហ្វឹកហ្វាត់ការងារដែលស៊ីគ្នានឹងចំណាប់អារម្មណ៍របស់ពួកគេនិងបង្កើតជំនាញដែលមានតម្លៃ។
- ☐ ក្នុងអំឡុងពេលរដូវក្ដៅ ធ្វើដំណើរកម្សាន្តតាមទីតាំងសាលារៀនដែលកូនអ្នកចាប់អារម្មណ៍។

**ថ្នាក់ទី 12**

- ☐ រៀបចំការប្រជុំជាមួយកូនរបស់អ្នក និងអ្នកប្រឹក្សាយោបល់សាលារៀនរបស់ពួកគេដើម្បីប្រាកដថាពួកគេកំពុងស្ថិតក្នុងដំណើរឆ្ពោះទៅរកការបញ្ចប់ការសិក្សា។
- ☐ បង្រួមចំនួនមហាវិទ្យាល័យ/សាលាបច្ចេកទេសដែលកូនរបស់អ្នកចាប់អារម្មណ៍ឲ្យនៅតិច។
- ☐ រំឭកកូនរបស់អ្នកឲ្យបំពេញនិងប្រគល់ពាក្យស្នើសុំចូលរៀននៅមហាវិទ្យាល័យ។
- ☐ រំឭកកូនរបស់អ្នកឲ្យសរសេរកថាខណ្ឌដាក់ពាក្យសុំ ប្រសិនបើចាំបាច់ និងត្រូវឲ្យគ្រូបង្រៀនម្នាក់ជួយត្រួតពិនិត្យសំណេរនោះ។
- ☐ រំឭកកូនរបស់អ្នកឲ្យប្រគល់ឯកសារចាំបាច់ទាំងអស់សម្រាប់ជំនួយហិរញ្ញវត្ថុ និង/ឬអាហារូបករណ៍ដែលមានផ្ដល់ជូន។ (ប្រគល់ពាក្យស្នើសុំ FAFSA និង PHEAA។ នៅថ្ងៃដំបូងដែល FAFSA មានផ្ដល់ជូននៅថ្ងៃទី1 ខែតុលា នៅ studentaid.ed.gov)
- ☐ ជួយកូនរបស់អ្នកក្នុងការបង្កើតប្រតិទិនមួយដែលរំលេចពីកាលបរិច្ឆេទសំខាន់ៗ និងកាលបរិច្ឆេទផុតកំណត់។
- ☐ ប្រសិនបើត្រូវការលិខិតបញ្ជាក់ ត្រូវរំឭកកូនរបស់អ្នកឲ្យស្នើសុំលិខិតនេះយ៉ាងតិចបួនសប្ដាហ៍មុនពេលកាលបរិច្ឆេទផុតកំណត់ពាក្យស្នើសុំ។
- ☐ រំឭកកូនរបស់អ្នកឲ្យចុះឈ្មោះសម្រាប់ SAT ឬ ACT ប្រសិនបើចាំបាច់។
- ☐ រៀបចំពេលវេលាជួបជាមួយអ្នកប្រឹក្សាយោបល់កូនរបស់អ្នក ដើម្បីធានាថាព្រឹត្តិបត្រពិន្ទុនៅវិទ្យាល័យ ត្រូវបានប្រគល់ទៅមហាវិទ្យាល័យដែលកូនរបស់អ្នកបានដាក់ពាក្យស្នើសុំចូលរៀន (វិច្ឆិកា-មីនា)។
- ☐ រំឭកកូនរបស់អ្នកដើម្បីធ្វើការថតចម្លងនូវឯកសារទាំងទាំងអស់ដែលពួកគេផ្ញើជូន និងឲ្យពួកគេអនុវត្តការតាមដានជាមួយសាលារៀនដើម្បីប្រាកដថា ពួកគេទទួលបានព័ត៌មានតាមការស្នើសុំ។
- ☐ ធ្វើការប្រៀបធៀបកញ្ចប់ថវិកាជំនួយហិរញ្ញវត្ថុដោយប្រុងប្រយ័ត្ន។ ប្រសិនបើអ្នកត្រូវការជំនួយ សូមជជែកជាមួយ

អ្នកប្រឹក្សាយោបល់របស់អ្នក ឬបុគ្គលិក MEP។

- ☐ ប្រសិនបើអ្នកមិនទាន់បានធ្វើវានៅឡើយ សូមទៅមើលមហាវិទ្យាល័យ/សាលាពាណិជ្ជសាស្ត្រដែលកូនរបស់អ្នកបានជ្រើសរើសនៅមុនពេលការទទួលឲ្យចូលរៀន។
- ☐ សូមពិនិត្យមើលលិខិតអនុញ្ញាតឲ្យចូលរៀន ឬលិខិតបដិសេធ ជាទូទៅត្រូវបានផ្ញើនៅមុនខែឧសភា។
- ☐ ត្រូវប្រាកដថា ថ្លៃឈ្នួលសាលានិងថ្លៃសេវារបស់កូនអ្នក ត្រូវបានបង់រួច។
- ☐ ធ្វើផែនការលំនៅដ្ឋាន និងម្ហូបអាហារសម្រាប់កូនរបស់អ្នក។
- ☐ រៀបចំកូនរបស់អ្នកសម្រាប់ដំណើរដ៏សប្បាយរីករាយនេះ។

# ការបង់ប្រាក់សម្រាប់ការអប់រំក្រោយមធ្យមសិក្សា

ដូចបង្ហាញនៅក្នុងតារាងនេះ មានជំនួយហិរញ្ញវត្ថុសំខាន់ៗចំនួនពីរ៖ អំណោយ (ប្រាក់ឧបត្ថម្ភ និង អាហារូបករណ៍) និងការជួយខ្លួនឯង (ប្រាក់កម្ចី ឬធ្វើការបណ្តើររៀនបណ្តើរ)។ កូនរបស់អ្នកអាចត្រូវការទាំងពីរ។ ពួកគេអាចទទួលបានជំនួយហិរញ្ញវត្ថុផ្អែកលើជំនួយដែលពួកគេទទួលបាន។ ពាក្យបច្ចេកទេសត្រូវបានពន្យល់នៅក្រោមដ្យាក្រាមនេះ។




## *ពាក្យគន្លឹះ*

**កម្ចីដោយផ្ទាល់ពីសហព័ន្ធ៖** កម្មវិធីមួយដែលផ្តល់ប្រាក់កម្ចីដែលមានការប្រាក់ទាបជូនដល់សិស្សក្រោយមធ្យមសិក្សានិងឪពុកម្តាយរបស់ពួកគេ។

**មូលនិធិឧបត្ថម្ភធនសហព័ន្ធ៖** ប្រាក់ឧបត្ថម្ភធនដែលរដ្ឋាភិបាលសហព័ន្ធសហរដ្ឋអាមេរិកផ្តល់ជូនដល់សិស្សានុសិស្សដែលកំពុងមានតម្រូវការដើម្បីធ្វើការបង់ប្រាក់នៅមហាវិទ្យាល័យ។

**ជំនួយហិរញ្ញវត្ថុ៖** ជំនួយហិរញ្ញវត្ថុ ពីរដ្ឋាភិបាលសហព័ន្ធដើម្បីជួយធ្វើការបង់ប្រាក់ដល់ការចំណាយលើការអប់រំនៅមហាវិទ្យាល័យដែលមានសិទ្ធិចូលរៀន ឬនៅសាលាវិជ្ជាជីវៈ។

**ហិរញ្ញប្បទាន៖** ជំនួយហិរញ្ញវត្ថុ ជាទូទៅផ្តោតជាសំខាន់លើតម្រូវការហិរញ្ញវត្ថុដែលពុំត្រូវការបង់ប្រាក់សងវិញ។

**ប្រាក់កម្ចី៖** សិស្សមហាវិទ្យាល័យ ឬឪពុកម្តាយរបស់ពួកគេបានខ្ចីប្រាក់ដើម្បីជួយបង់ថ្លៃមហាវិទ្យាល័យ។

**PHEAA៖** (ទីភ្នាក់ងារជំនួយការអប់រំនៅឧត្តមសិក្សារដ្ឋផេនស៊ីលវ៉ានៀ) គឺផ្អែកលើតម្រូវការផ្នែកហិរញ្ញវត្ថុ។

**ប្រាក់កម្ចីបន្ថែម៖** ប្រាក់កម្ចីទទួលបានពីស្ថាប័នឯកជន មានសម្រាប់បង់ប្រាក់ការចំណាយនៅមហាវិទ្យាល័យ អាស្រ័យលើប្រវត្តិឥណទានរបស់អ្នក។

**ប្រាក់កម្ចីសិស្សពីវិស័យឯកជន៖** ប្រាក់កម្ចីទទួលបានពីស្ថាប័នឯកជន មានសម្រាប់បង់ប្រាក់ការចំណាយនៅមហាវិទ្យាល័យ អាស្រ័យលើប្រវត្តិឥណទានរបស់អ្នក។

**អាហារូបករណ៍៖** ប្រាក់ដែលផ្តល់ទៅសិស្សនៅមហាវិទ្យាល័យដោយសារសមិទ្ធិផល សមត្ថភាព ឬសាវតាពិសេស។

**ប្រាក់កម្ចីឧបត្ថម្ភធន៖** ផ្អែកលើតម្រូវការហិរញ្ញវត្ថុ។ រដ្ឋាភិបាលផ្តល់ប្រាក់ឧបត្ថម្ភធន (ដើម្បីបង់) ការប្រាក់ចំពោះប្រាក់កម្ចី នៅពេលសិស្សកំពុងនៅសាលារៀន និងក្នុងរយៈពេលអនុគ្រោះបន្ទាប់ពីរយៈពេលប្រាំមួយខែបន្ទាប់ពីការបញ្ចប់ការសិក្សា។

**ប្រាក់កម្ចីគ្មានឧបត្ថម្ភធន៖** ប្រាក់កម្ចីដែលមិនផ្អែកលើតម្រូវការហិរញ្ញវត្ថុ។ កុមារនឹងត្រូវគិតការប្រាក់ពីពេលអ្នកខ្ចីប្រាក់រហូតដល់ប្រាក់កម្ចីត្រូវសងរួចរាល់។

**ធ្វើការបណ្តើរៀនបណ្តើរ៖** ការងារដែលផ្តល់ជូនតាមរយៈមហាវិទ្យាល័យ និងទទួលបានមូលនិធិពីរដ្ឋាភិបាលដើម្បីជួយសិស្សបង់ថ្លៃមហាវិទ្យាល័យ។

សម្រាប់ព័ត៌មានលម្អិតអំពីកម្មវិធីជំនួយសិស្សរបស់សហព័ន្ធ រួមមានចំនួនទឹកប្រាក់ប្រចាំឆ្នាំអតិបរមា និងអត្រាការប្រាក់កម្ចីជាដើម, សូមចូលទៅកាន់ www.*StudentAid.gov/parent*។

## តើមានអត្ថប្រយោជន៍អ្វីខ្លះដែលកូនរបស់អ្នកបន្តការអប់រំបន្ទាប់ពីបញ្ចប់ថ្នាក់វិទ្យាល័យ?

តើកូនរបស់អ្នកគិតគូអំពីការឈប់រៀនដើម្បីចូលធ្វើការ ដើម្បីឲ្យពួកគេអាចរកប្រាក់ចំណូលជួយដល់គ្រួសារមែនទេ? ការសម្រេចចិត្តនេះ មានផលប៉ះពាល់យ៉ាងខ្លាំងដល់អនាគតកូនរបស់អ្នក! និយាយដោយបើកចំហអំពីក្តីកង្វល់នានាជាមួយនឹងអ្នកប្រឹក្សាយោបល់សាលារៀនកូនរបស់អ្នក គ្រូបង្រៀនដែលគួរទុកចិត្ត និងបុគ្គលិក PA-MEP។ ពួកគេនឹងជួយអ្នកពិនិត្យលើជម្រើសផ្សេងៗទៀត។

ក្រាហ្វិកនេះ (ដែលមានក្នុងពេលនេះ) បង្ហាញថា លទ្ធផលនៃការអប់រំដែលល្អប្រសើរនៅក្នុងការទទួលបានប្រាក់ចំណូលកម្រិតខ្ពស់។ សិស្សដែលបញ្ចប់ការសិក្សាពីវិទ្យាល័យ នឹងរកប្រាក់ចំណូលបានកាន់តែច្រើនក្នុងមួយសប្តាហ៍ជាជាងសិស្សដែលពុំមានសញ្ញាបត្រវិទ្យាល័យ ជាពិសេសក្នុងអំឡុងពេលនៃ

វគ្គសិក្សាក្នុងមួយជីវិតរបស់គេ។ នេះបង្ហាញពីចំណុចដែលការសម្រេចចិត្តដើម្បីឈប់រៀននៅវិទ្យាល័យដើម្បីចូលធ្វើការ ពិតជាមានផលប៉ះពាល់យ៉ាងខ្លាំង។

**អត្រាអត់ការងារធ្វើ និងប្រាក់ចំណូលដោយការទទួលបានការអប់រំ ឆ្នាំ2016៖**




## វិថីពីវិទ្យាល័យឆ្ពោះទៅកាន់កម្លាំងពលកម្ម



មានវិធីជាច្រើនសម្រាប់កូនរបស់អ្នកទទួលបានពីវិទ្យាល័យចំពោះកម្លាំងពលកម្ម។ វាអាចមានជំហាន ដូចគ្នា ឬជំហានខុសគ្នានៅពេលកំពុងអនុវត្តការងារ។

## ការដាក់ពាក្យស្នើសុំដោយឥតគិតថ្លៃសម្រាប់ជំនួយសិស្សរបស់សហព័ន្ធ FAFSA)

FAFSA គឺជាពាក្យស្នើសុំស្តង់ដា ដែលប្រើប្រាស់ដើម្បីដាក់ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុពីកម្មវិធីសហព័ន្ធទាំងអស់។ ដំណើរការនៃការដាក់ពាក្យស្នើសុំ គឺឥតគិតថ្លៃ ហើយទម្រង់នេះអាចស្វែងរកបាននៅលើប្រព័ន្ធអនឡាញ។ FAFSA គឺជាគន្លឹះដ៏សំខាន់របស់កូនអ្នកដើម្បីទទួលបានប្រាក់ឧបត្ថម្ភ ការវាយតម្លៃការងារ ប្រាក់កម្ចី និងអាហារូបករណ៍មួយចំនួនទៀតផងដែរ។

ឪពុកម្តាយក៏អាចបង្កើតផែនការសន្សំប្រាក់មហាវិទ្យាល័យ 529 បានផងដែរ - ឪពុកម្តាយអាចចាប់ផ្តើមសន្សំប្រាក់តាមរយៈនិយោជក ឬស្ថាប័នហិរញ្ញវត្ថុរបស់ពួកគេ។ ផែនការ 529 គឺផែនការសន្សំប្រាក់អត្ថប្រយោជន៍ពន្ធ ដែលបានបង្កើតឡើងដើម្បីលើកទឹកចិត្តដល់ការសន្សំប្រាក់សម្រាប់ចំណាយការអប់រំក្នុងពេលអនាគត។ ផែនការ 529 ហៅជាផ្លូវការស្របច្បាប់ថា "ផែនការសម្រាប់បង់ថ្លៃសាលា" គឺទទួលបានការឧបត្ថម្ភដោយរដ្ឋ ទីភ្នាក់ងាររដ្ឋ ឬស្ថាប័នអប់រំ និងទទួលបានការអនុញ្ញាតដោយ មាត្រា 529 នៃក្រមប្រាក់ចំណូលអន្តរជាតិ។ អ្នកអាចប្រើប្រ្រាស់ផែនការ 529 ដើម្បីបង់ចំណាយការអប់រំនៅឧត្តមសិក្សានៅតាមមហាវិទ្យាល័យ និងសាកលវិទ្យាល័យភាគច្រើន និងតាមបណ្តាសាលាបច្ចេកទេស និងសាលាវិជ្ជាជីវៈជាច្រើនផ្សេងទៀត។ កម្មវិធីសន្សំប្រាក់សម្រាប់មហាវិទ្យាល័យ 529 រដ្ឋផេនស៊ីលវ៉ានៀ ផ្តល់ជូននូវផែនការសន្សំប្រាក់ចំនួនពីរ។ ផែនការសន្សំប្រាក់ដែលមានការធានា 529 រដ្ឋផេនស៊ីលវ៉ានៀ (GSP) គឺជាផែនការដែលមានហានិភ័យទាប ដែលជួយឲ្យការសន្សំប្រាក់របស់អ្នកមានកម្រិតប្រហាក់ប្រហែលនឹងការកើនឡើងនៃថ្លៃសាលានៅក្នុងការអប់រំឧត្តមសិក្សា។ ផែនការវិនិយោគ 529 រដ្ឋផេនស៊ីលវ៉ានៀ (IP) អាចឲ្យអ្នកជ្រើសរើសពានពីជម្រើសនៃការវិនិយោគចំនួន 16 ពី The Vanguard Group។ ពុំមានការកំណត់ចំពោះប្រាក់ចំណូលនោះទេ ហើយមនុស្សម្នាក់ៗអាចចូលរួមបាន។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ https://www.pa529.com។

## អាហារូបករណ៍

អាហារូបករណ៍ មានសម្រាប់សិស្សទាំងអស់កំពុងស្វែងរកការអប់រំនៅមហាវិទ្យាល័យ។ ប្រភេទនៃអាហារូបករណ៍រួមមាន៖ ការសិក្សា អត្តពលិក សម្រាប់ក្រុមជនជាតិណាមួយ ស្ត្រី និងសេវាសហគមន៍ក្នុងផ្សេងទៀត។ ចំណុចមួយចំនួនបន្ថែមទៀតដែលធ្វើឲ្យពាក្យស្នើសុំរបស់អ្នកមានលក្ខណៈលេចធ្លោ៖

- ម៉ោងការងារស្ម័គ្រចិត្ត
- ការចុះឈ្មោះចូលរៀនក្នុងក្លឹបសាលា
- ជាជនសកម្មនៅក្នុងសាលា
- ជាជនសកម្មនៅក្នុងសហគមន៍

# កំណត់ចំណាំ និងធនធានបន្ថែម